**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៩ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតតំបន់ការពារទេសភាព "សំបូរព្រៃគុក"**

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតតំបន់ការពារទេសភាព «សំបូរព្រៃគុក» ដែលមានផ្ទៃដីសរុបចំនួន ៤៣៨ (បួនរយសាមសិបប្រាំបី) ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកាគោល (Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
| 1 | 503863 | 1424762 | 11 | 505188 | 1424401 | 21 | 504761 | 1421874 | 31 | 503453 | 1421183 |
| 2 | 503490 | 1424906 | 12 | 505222 | 1423946 | 22 | 504577 | 1421405 | 32 | 503500 | 1421436 |
| 3 | 503503 | 1425155 | 13 | 505136 | 1423697 | 23 | 504364 | 1421305 | 33 | 503642 | 1421641 |
| 4 | 503767 | 1425127 | 14 | 504991 | 1423729 | 24 | 503796 | 1420858 | 34 | 503536 | 1421983 |
| 5 | 503995 | 1425191 | 15 | 504998 | 1423497 | 25 | 503598 | 1420919 | 35 | 503743 | 1422751 |
| 6 | 503991 | 1425427 | 16 | 505202 | 1423468 | 26 | 503765 | 1420613 | 36 | 504004 | 1423009 |
| 7 | 504300 | 1425206 | 17 | 505131 | 1423283 | 27 | 503673 | 1420411 | 37 | 504121 | 1423438 |
| 8 | 504207 | 1424977 | 18 | 504926 | 1423006 | 28 | 503411 | 1420548 | 38 | 504072 | 1423706 |
| 9 | 504690 | 1424849 | 19 | 504880 | 1422671 | 29 | 503307 | 1420774 | 39 | 504182 | 1423910 |
| 10 | 504915 | 1424611 | 20 | 504841 | 1422458 | 30 | 503341 | 1420990 | 40 | 504185 | 1424622 |

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា និងការពារសោភ័ណ្ឌភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ និងវប្បធម៌
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់ប្រាសាទ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណៈជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់
- ថែរក្សាការពារ វប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន

**មាត្រា៣.-**

ផ្ទៃដីនៃអនុក្រឹត្យតំបន់ការពារទេសភាព«សំបូរព្រៃគុក» នេះ មិនរួមបញ្ចូលដីកម្មសិទ្ធិឯកជន និងដីប្រើប្រាស់ជាប្រយោជន៍សាធារណៈ។



www.pheakdeylaw.com

**មាត្រា៤.-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ការពារទេសភាព«សំបូរព្រៃគុក» ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តកំពង់ធំ និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីជានាកិច្ចគាំពារបរិស្ថាន ការអភិរក្សប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

ផែនទី កំណត់តំបន់ការពារទេសភាព «សំបូរព្រៃគុក» ស្ថិតក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃ ១៣ ខែ មីនា ឆ្នាំរកា ឯកស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ២០១៨




ថ្ងៃ ... ខែ មាឃ ឆ្នាំរកា ឯកស័ក ព.ស.២៥៦១
ធ្វើនៅកំពង់ធំ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៨
អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ
សុខ-លូ

ថ្ងៃ ... ១២ កើត ខែ ផល្គុន ឆ្នាំរកា ឯកស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៨
រដ្ឋមន្ត្រីក្រសួងបរិស្ថាន
សាយ សំអាល់

សញ្ញាសម្គាល់

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ព្រៃដុះឡើងវិញ
- ផ្លូវ
- ទឹក
- ព្រំប្រទល់តំបន់ការពារទេសភាពសំបូរព្រៃគុក
- ដីកុំមានគម្របព្រៃឈើ

និយាមការគោល

| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 503863 | 1424762 | 11 | 505188 | 1424401 | 21 | 504761 | 1421874 | 31 | 503453 | 1421183 |
| 2 | 503490 | 1424906 | 12 | 505222 | 1423946 | 22 | 504577 | 1421405 | 32 | 503500 | 1421436 |
| 3 | 503503 | 1425155 | 13 | 505136 | 1423697 | 23 | 504364 | 1421305 | 33 | 503642 | 1421641 |
| 4 | 503767 | 1425127 | 14 | 504991 | 1423729 | 24 | 503796 | 1420858 | 34 | 503536 | 1421983 |
| 5 | 503995 | 1425191 | 15 | 504998 | 1423497 | 25 | 503598 | 1420919 | 35 | 503743 | 1422751 |
| 6 | 503991 | 1425427 | 16 | 505202 | 1423468 | 26 | 503765 | 1420613 | 36 | 504004 | 1423009 |
| 7 | 504300 | 1425206 | 17 | 505131 | 1423283 | 27 | 503673 | 1420411 | 37 | 504121 | 1423438 |
| 8 | 504207 | 1424977 | 18 | 504926 | 1423006 | 28 | 503411 | 1420548 | 38 | 504072 | 1423706 |
| 9 | 504690 | 1424849 | 19 | 504880 | 1422671 | 29 | 503307 | 1420774 | 39 | 504182 | 1423910 |
| 10 | 504915 | 1424611 | 20 | 504841 | 1422458 | 30 | 503342 | 1420990 | 40 | 504185 | 1424622 |



COORDINATE SYSTEM
Projection: UTM
Zone: 48
Horizontal Datum: WGS 84

មាត្រដ្ឋាន 1:30,000
0 0.25 0.5 1 km

ផ្ទៃដី តំបន់ការពារទេសភាព «សំបូរព្រៃគុក» សរុប ៤៣៨ ហិកតា